# ទម្រង់បែបបទនៃបណ្តឹងតវ៉ា

www.ibac.vic.gov.au

ទម្រង់បែបបទនេះសួរសំណួរសំខាន់ៗមួយចំនួនទាក់ទងនឹងបណ្តឹងតវ៉ារបស់អ្នក។ ព័ត៌មានរបស់អ្នកជួយឱ្យយើងសម្រេចចិត្តថាការឆ្លើយតបអ្វីខ្លះដែលត្រូវការ ប៉ុន្តែវាក៏ជួយស៊ើបអង្កេតលើអំពើពុករលួយ និងបញ្ហា និងហានិភ័យនៃការប្រព្រឹត្តិមិនត្រឹមត្រូវនានាបានកាន់តែទូលំទូលាយ នៅទូទាំងផ្នែកសាធារណៈ។ ប្រសិនបើយើងត្រូវការព័ត៌មានបន្ថែម យើងនឹងទាក់ទងអ្នក។

## នៅមុនពេលធ្វើបណ្តឹងតវ៉ា

- យល់អំពី IBAC ជានរណា អាច និងមិនអាចស៊ើបអង្កេតអ្វីខ្លះ និងពិនិត្យមើលប្រសិនបើយើងជាទីភ្នាក់ងារត្រឹមត្រូវឬអត់នៅក្នុងរដ្ឋវិចតូរៀ (Victoria) ដើម្បីទាក់ទងជាមួយនឹងការព្រួយបារម្ភរបស់អ្នក។
- ត្រូវឱ្យច្បាស់លាស់ថាអ្នកកំពុងប្តឹងតវ៉ាជាមួយអ្នកណា ហើយកំពុងប្តឹងតវ៉ាលើរឿងអ្វី។
- យល់អំពីជម្រើសឯកជនភាពរបស់អ្នក ហើយអ្វីខ្លះកើតឡើងចំពោះបណ្តឹងតវ៉ារបស់អ្នក។
- ប្រសិនបើអ្នកបានប្តឹងតវ៉ារួចហើយទៅទីភ្នាក់ងារមួយទៀត សូមផ្តល់ព័ត៌មានលម្អិតទាំងនោះ។
- ប្រសិនបើអ្នកកំពុងប្តឹងតវ៉ាជំនួសមុខឱ្យមនុស្សម្នាក់ផ្សេងទៀត អ្នក**ត្រូវតែ**មានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ពួកគេ នៅមុនពេលបំពេញទម្រង់បែបបទនេះ (មើលឧបសម្ព័ន្ធ A)។

## ឯកជនភាព

IBAC គ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដោយប្រុងប្រយ័ត្ន និងស្របតាមច្បាប់ដែលពាក់ព័ន្ធ។ ប្រសិនបើអ្នកធ្វើការប្តឹងតវ៉ា ហើយ IBAC កំណត់សម្រេចបញ្ជូនបណ្តឹងតវ៉ារបស់អ្នកទៅទីភ្នាក់ងារមួយទៀត ព័ត៌មានដែល អ្នកផ្តល់ទៅឱ្យ IBAC, រួមមានព័ត៌មានលម្អិតផ្ទាល់ខ្លួន របស់អ្នក នឹងត្រូវបានបញ្ជូនបន្តទៅទីភ្នាក់ងារនោះ សម្រាប់គោលបំណងដោះស្រាយបណ្តឹងតវ៉ា របស់អ្នក។

សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបដែល IBAC គ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក សូមអានផ្នែក ឯកជនភាពរបស់អ្នក នៃគេហទំព័ររបស់យើង www.ibac.vic.gov.au.

## របៀបបំពេញទម្រង់បែបបទនេះ

- សូមសរសេរឱ្យច្បាស់ ដោយប្រើប៊ិចពណ៌ខ្មៅ ឬពណ៌ខៀវ។
- សូមអានសំណួរនីមួយៗដោយប្រុងប្រយ័ត្ន។
- ផ្តល់ច្បាប់ចម្លងនៃឯកសារណាមួយដើម្បីជួយគាំទ្រដល់
- ព័ត៌មាន ដែលមាននៅក្នុងបណ្តឹងតវ៉ារបស់អ្នក។ សូមកុំផ្តល់ច្បាប់ដើម។

### ផ្ញើទម្រង់បែបបទនេះទៅ៖

តាមរយៈសំបុត្រ GPO Box 24234 Melbourne Vic 3001

អ៊ីមែល info@ibac.vic.gov.au
ទូរសារ (03) 8635 6444

## ត្រូវការជំនួយឬ?

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបំពេញទម្រង់បែបបទនេះ សូមហៅទូរសព្ទមកយើងតាមលេខ **1300 735 135**។

## សេវាកម្មនានាសម្រាប់មនុស្សថ្លង់ មានបញ្ហា ក្នុងការស្តាប់ ឬនិយាយ

- ទូរសព្ទអ្នកប្រើប្រាស់ TTY តាមលេខ 1800 555 677 បន្ទាប់មកស្នើសុំភ្ជាប់ទៅលេខ 1300 735 135។
- ទូរសព្ទអ្នក ប្រើប្រាស់ដែលនិយាយ និងស្តាប់ តាមលេខ 1800 555 727 បន្ទាប់មកស្នើសុំភ្ជាប់ទៅលេខ 1300 735 135។
- អ្នកប្រើប្រាស់សេវាបញ្ជូនបន្តអ៊ីនធឺណិត ភ្ជាប់ទៅសេវាបញ្ជូនបន្តថ្នាក់ជាតិ និងស្នើសុំភ្ជាប់ទៅលេខ 1300 735 135។

## សេវាកម្មនានាសម្រាប់មនុស្សដែលត្រូវការអ្នកបកប្រែផ្ទាល់មាត់ ឬការបកប្រែសរសេរ

ទម្រង់បែបបទនេះមានជាង 20 ភាសានៅលើគេហទំព័ររបស់យើងនៅឯ www.ibac.vic.gov.au/mylanguage.

សេវាបកប្រែផ្ទាល់មាត់ និងបកប្រែសរសេរ (TIS) មានអ្នកបកប្រែផ្ទាល់មាត់ច្រើនជាង 120 ភាសា និងគ្រាមភាសា។

ដើម្បីប្រើប្រាស់សេវាកម្មនេះ សូមទូរសព្ទទៅ៖

- IBAC តាមលេខ 1300 735 135, ឬ
- ទៅ TIS ដោយផ្ទាល់តាមលេខ 131 450។

## ព័ត៌មានបន្ថែម

សូមអាន *សន្លឹកព័ត៌មានស្តីពីការរាយការណ៍អំពើពុករលួយ និងការប្រព្រឹត្តិមិនត្រឹមត្រូវ*, របស់យើងដែលមាននៅឯ www.ibac.vic.gov.au។

independent broad-based anti-corruption commission
Victoria

# ផ្នែក A – ព័ត៌មានលម្អិតរបស់អ្នក

**1. តើអ្នកចង់ធ្វើការប្ដឹងតវ៉ាដោយអនាមិកឬ?**

អ្នកអាចធ្វើការប្ដឹងតវ៉ាដោយអនាមិកបាន។ នេះរួមមានការបន្តនៅជាអនាមិកពី IBAC និងរារាំងយើងក្នុងការទាក់ទងអ្នកដើម្បីស្វែងរកព័ត៌មានបន្ថែម ឬក្នុងការពិភាក្សាលើបណ្ដឹងតវ៉ា ប្រសិនបើអ្នកទាក់ទងយើង។

☐ បាទ/**ចាស ទៅកាន់សំណួរទី 15** ☐ ទេ **ទៅកាន់សំណួរទី 2**

**2. ឈ្មោះរបស់អ្នក**

**នាមខ្លួន**

**ឈ្មោះកណ្ដាល**

**នាមត្រកូល**

**3. តើអ្នកធ្លាប់ប្ដឹងតវ៉ាទៅ IBAC អំពីរឿងនេះរួចហើយឬ?**

☐ បាទ/ចាស ☐ ទេ

**ប្រសិនបើ បាទ/ចាស សូមផ្ដល់លេខយោង IBAC របស់អ្នកខាងក្រោម រួចទៅកាន់សំណួរទី 29**

**4. តើអ្នកមានអាយុក្រោម 18 ឆ្នាំឬ?**

☐ បាទ/ចាស ☐ ទេ

**5. តើនៅផ្ទះ អ្នកនិយាយភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេសឬ?**

☐ បាទ/ចាស ☐ ទេ

ប្រសិនបើ បាទ/ចាស តើអ្វីជាភាសាពេញចិត្តរបស់អ្នក?

**តើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ឬអ្នកបកប្រែសរសេរដើម្បីធ្វើទំនាក់ទំនងជាមួយ IBAC ឬ?**

☐ បាទ/ចាស ☐ ទេ

**6. តើអ្នកត្រូវការឧបករណ៍ជំនួយក្នុងការធ្វើទំនាក់ទំនង ឬទេ?**

☐ បាទ/ចាស ☐ ទេ

ប្រសិនបើ បាទ/ចាស សូមពណ៌នាឧបករណ៍ជំនួយ ដែលត្រូវការ។

**7. ភេទ**

☐ ស្ត្រី

☐ បុរស

☐ បានពណ៌នាដោយខ្លួនឯង (សូមបញ្ជាក់)៖

☐ ពេញចិត្តមិននិយាយ

**8. តើអ្នកជាជនជាតិដើម Aboriginal ឬអ្នកកោះ Torres Strait Islander ឬ?**

☐ ទេ

☐ បាទ/ចាស, ជនជាតិដើម Aboriginal

☐ បាទ/ចាស, អ្នកកោះ Torres Strait Islander

☐ បាទ/ចាស, ទាំងពីរ គឺជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait Islander

☐ ពេញចិត្តមិននិយាយ

**9. ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង**

សូមផ្ដល់យ៉ាងហោចណាស់មួយ។

**អាសយដ្ឋានអ៊ីមែល**

**លេខទូរសព្ទ**

**អាសយដ្ឋានផ្ញើ**

| | |
|---|---|
| ផ្ទះល្វែង (Unit)/លេខផ្ទះ និងឈ្មោះផ្លូវ (ឬ PO Box, RMB, RRB) | |
| ក្រុង/ជាយក្រុង | |
| លេខកូដប្រៃសណីយ៍ | |
| រដ្ឋ | - |
| ប្រទេស | |

**តើវិធីល្អបំផុតមួយណាដើម្បីទាក់ទងអ្នក?**

☐ អ៊ីមែល ☐ ទូរសព្ទ ☐ បញ្ញើ

# ផ្នែក B – ព័ត៌បណ្ដឹងតវ៉ារបស់អ្នក

**10. តើអ្នកកំពុងធ្វើការប្ដឹងតវ៉ានេះជំនួសមុខឱ្យមនុស្សម្នាក់ទៀតឬ?**

អ្នកអាចធ្វើការប្ដឹងតវ៉ានេះជំនួសមុខឱ្យមនុស្សម្នាក់ទៀតបាន។ ទោះបីយ៉ាងណាក៏ដោយ យើងនឹងត្រូវការដើម្បីបង្ហាញថាមនុស្សនោះដឹងអំពីបណ្ដឹតវ៉ារបស់អ្នក ហើយបានអនុញ្ញាតផ្ដល់សិទ្ធិឱ្យអ្នក ដើម្បីធ្វើសកម្មភាពជំនួសឱ្យពួកគេ។

☐ បាទ/ចាស **ទៅកាន់សំណួរទី 11** ☐ ទេ **ទៅកាន់សំណួរទី 15**

**11. តើមនុស្សម្នាក់នេះដឹងថាអ្នកកំពុងធ្វើការប្ដឹងតវ៉ានេះជំនួសឱ្យពួកគេទេ?**

ប្រសិនបើអ្នកកំពុងប្ដឹងតវ៉ាជំនួសឱ្យនរណាម្នាក់ផ្សេងទៀត នោះអ្នកត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ពួកគេ។ IBAC នឹងត្រូវបានទាក់ទងដើម្បីពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃការយល់ព្រម។

☐ បាទ/ចាស ☐ ទេ

**12. ប្រសិនបើឆ្លើយ បាទ/ចាស ចំពោះសំណួរទី 10 និង 11 សូមផ្ដល់ព័ត៌មានលម្អិតអំពីមនុស្សដែលអ្នកកំពុងធ្វើការប្ដឹងតវ៉ាជំនួស។**

**នាមខ្លួន**

**ឈ្មោះកណ្ដាល**

**នាមត្រកូល**

សូមផ្ដល់វិធីយ៉ាងហោចណាស់មួយដើម្បីទាក់ទងមនុស្សនោះ។

**អាសយដ្ឋានអ៊ីមែល**

**លេខទូរសព្ទ**

**អាសយដ្ឋានផ្ញើ**

| | |
|---|---|
| ផ្ទះល្វែង (Unit)/លេខ ផ្ទះ និងឈ្មោះផ្លូវ (ឬ PO Box, RMB, RRB) | |
| ក្រុង/ជាយក្រុង | |
| លេខកូដប្រៃសណីយ៍ | |
| រដ្ឋ | - |
| ប្រទេស | |

**13. តើអ្នកមានទំនាក់ទំនងអ្វីជាមួយអ្នកប្ដឹង?**

☐ អាណាព្យាបាលផ្លូវច្បាប់

☐ សមាជិកគ្រួសារ មិត្តភ័ក្តិ ឬសហការី

☐ អ្នកតស៊ូមតិផ្លូវការ (មានន័យថា មេធាវី បុគ្គលិកសង្គមកិច្ច។ល។)

☐ សហការីការងារ

☐ ផ្សេងទៀត (សូមបញ្ជាក់)៖

**14. សូមពន្យល់អំពីមូលហេតុដែលអ្នកកំពុងធ្វើការប្ដឹងតវ៉ានេះជំនួសមុខឱ្យមនុស្សម្នាក់ទៀត។**

**15. តើការិយាល័យរដ្ឋាភិបាលរដ្ឋវិចតូរៀ ឬស្ថាប័នមួយណាដែលអ្នកកំពុងធ្វើការប្ដឹងតវ៉ាអំពី?**

☐ ប៉ូលីសវិចតូរៀ (រួមមានមន្ត្រីផ្តល់សេវាការពារ មន្ត្រីប៉ូលីស មន្ត្រីឃុំឃាំង សមាជិកប៉ូលីសថ្មី និងនិយោជិតនានា)

☐ សមាជិកសភា

☐ ក្រសួង/ទីភ្នាក់ងាររដ្ឋាភិបាលនៅតាមរដ្ឋ

☐ ចៅក្រម ឬចៅក្រមថ្នាក់ក្រោម

☐ ក្រុមប្រឹក្សា (Council)

☐ មន្ទីរពេទ្យសាធារណៈ

☐ សាលាបឋមសិក្សា ឬអនុវិទ្យាល័យនៅតាមរដ្ឋ

☐ ផ្សេងទៀត (សូមបញ្ជាក់)៖

| |
|---|
| |

**16. តើអ្នកបានប្តឹងតវ៉ាទៅទីភ្នាក់ងារមួយទៀតកាលពីពេលមុនអំពីរឿងនេះទេ?**

☐ បាទ/**ចាស ទៅកាន់សំណួរទី 17** ☐ ទេ **ទៅកាន់សំណួរទី 18**

**17. តើទីភ្នាក់ងាមួយណាដែលអ្នកបានប្តឹងទៅ តើពេលណាដែលអ្នកបានប្តឹងតវ៉ា ហើយទទួលបានលទ្ធផលយ៉ាងដូចម្តេចដែរ?**

សូមផ្តល់សេចក្តីសង្ខេប និងភ្ជាប់ច្បាប់ចម្លងនៃការធ្វើទំនាក់ទំនងដែលពាក់ព័ន្ធណាមួយ។

| |
|---|
| |

**18. សូមផ្តល់ព័ត៌មានលម្អិតអំពីបណ្តឹងតវ៉ារបស់អ្នក។**
ពណ៌នាឱ្យបានពិស្តារអំពីការប្រព្រឹត្តិដែលមានលក្ខណៈពុករលួយ ឬការប្រព្រឹត្តិមិនត្រឹមត្រូវរបស់ប៉ូលិសដែលអ្នកជឿថា បានកើតឡើង។ រួមមានឈ្មោះមនុស្ស តួនាទីរបស់ពួកគេ ប្រសិនបើដឹង និងអង្គការដែលពាក់ព័ន្ធ។

**19. តើការប្រព្រឹត្តិនោះបានកើតឡើងនៅពេលណា?**

ប្រសិនបើអ្នកមិនដឹងពេលវេលា ឬកាលបរិច្ឆេទជាក់លាក់ទេ សូមផ្តល់ពេលវេលា ឬកាលបរិច្ឆេទប្រហាក់ប្រហែល ឧទាហរណ៍ ខែមករា ឆ្នាំ 2013។ ប្រសិនបើការប្រព្រឹត្តិបានកើតឡើងច្រើនជាងមួយដង សូមរាយជាបញ្ជីនូវរយៈកាលនៃពេលវេលា ប្រហាក់ប្រហែល។

**20. តើការប្រព្រឹត្តិដែលអ្នកកំពុងប្តឹងតវ៉ាបានកើតឡើងយូរជាង 12 ខែកន្លងទៅឬ?**

☐បាទ/ចាស **ទៅកាន់សំណួរទី 21** ☐ទេ **ទៅកាន់សំណួរទី 22**

**21. សូមពន្យល់មូលហេតុដែលអ្នកមិនបានធ្វើបណ្តឹងតវ៉ានេះទៅ IBAC ឱ្យបានលឿនជាងនេះ។**

យើងយល់ថាអាចមានហេតុផលមួយចំនួនចំពោះការពន្យារពេលក្នុងការប្តឹងតវ៉ាទៅ IBAC។ វាជួយឱ្យយើងវាយតម្លៃលើ បណ្តឹងតវ៉ារបស់អ្នក ប្រសិនបើអ្នកអាចពន្យល់អំពីការពន្យារពេលហួសពី 12 ខែ។

**22. តើការប្រព្រឹត្តិនោះបានកើតឡើងនៅកន្លែងណា?**

សូមផ្តល់ទីតាំង រួមមានជាយក្រុង/ក្រុង និងអាសយដ្ឋាន ឬឈ្មោះកន្លែង ប្រសិនបើដឹង។
ឧទាហរណ៍៖ West Smithtown Police Station, 49 Main Street, Smithtown។

**23. តើអ្នកមានព័ត៌មានជាក់លាក់ណាមួយផ្សេងទៀតដែលអ្នកចង់ផ្តល់ទេ?**

ឧទាហរណ៍៖ លេខគណនី លេខគ្រឿងសម្គាល់ ការចុះបញ្ជីរថយន្ត ។ល។

**24. តើអ្នកមានអ៊ីមែល រូបថត វីដេអូ ឬឯកសារគាំទ្រណាមួយផ្សេងទៀតទេ?**

☐ បាទ/ចាស ☐ ទេ

ប្រសិនបើ បាទ/ចាស សូមភ្ជាប់ ឬបញ្ចូលច្បាប់ចម្លង (កុំផ្តល់ច្បាប់ដើម)។ ជាជម្រើស ប្រសិនបើអ្នកបាន ផ្តល់ព័ត៌មានទំនាក់ទំនងលម្អិត នោះ IBAC អាចទាក់ទងអ្នកដើម្បីស្នើសុំវត្ថុទាំងនេះ។

**25. តើមានផលប៉ះពាល់អ្វីខ្លះនៃអំពើប្រព្រឹត្តិដែលអ្នកកំពុងប្តឹងតវ៉ា?**

ឧទាហរណ៍៖ របួសស្នាម ការបាត់បង់ហិរញ្ញវត្ថុ ការបាត់បង់ផ្ទាល់ខ្លួន ឬការបាត់បង់អាជីព។

**26. តើមានអ្នកណាម្នាក់ផ្សេងទៀតធ្វើជាសាក្សីលើអំពើប្រព្រឹត្តិនោះទេ?**

☐បាទ/ចាស ☐ទេ

**ព័ត៌មានលម្អិតសាក្សី**

ឈ្មោះ ឬពណ៌នាសាក្សីណាម្នាក់ ហើយអ្វីខ្លះដែលអ្នកជឿថាពួកគេដឹង ឬបានឃើញ។

| |
|---|
| |

**27. តើមានអ្វីបន្ថែមទៀតដែលអ្នកចង់ប្រាប់យើងអំពីស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកទាក់ទងនឹងបណ្តឹងតវ៉ានេះទេ?**

ឧទាហរណ៍៖ ការព្រួយបារម្ភអំពីការផ្លាញ់គប ការសម្លុត ឬការរើសអើង។

| |
|---|
| |

**28. តើអ្នកចង់ស្វែងរកលទ្ធផលយ៉ាងម៉េចដែរតាមរយៈការប្តឹងតវ៉ានេះ?**

សូមសម្គាល់ថា IBAC ធ្វើការស៊ើបអង្កេតលើអំពើពុករលួយផ្នែកសាធារណៈធ្ងន់ធ្ងរ និងការប្រព្រឹត្តិមិនត្រឹមត្រូវធ្ងន់ធ្ងររបស់ប៉ូលីស។ យើងមិនអាចពិចារណា ឬផ្តល់សំណង ឬពិចារណាលើគុណសម្បត្តិនៃសេចក្តីសម្រេច ឬដីកាបង្គាប់ផ្នែកតុលាការ(កគតិយុត្តិ)បានទេ។

**29. ប្រសិនបើអ្នកបានប្តឹងតវ៉ាពីមុនមកទៅ IBAC អំពីរឿងនេះ សូមផ្តល់ព័ត៌មានបន្ថែមណាមួយដែលអ្នកចង់រួមបញ្ចូលទាក់ទងនឹងបណ្តឹងតវ៉ាដែលមានស្រាប់របស់អ្នក។**

# ព័ត៌មានសំខាន់

IBAC អនុលោមតាមច្បាប់ឯកជនភាពរដ្ឋវិក្តូរៀ នៅពេលប្រមូល និងគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន និង ព័ត៌មានសុខភាព។

*សេចក្តីថ្លែងអំពីព័ត៌មានសុខភាពផ្ទាល់ខ្លួន និងព័ត៌មានសេរីប*របស់ IBAC មាននៅលើគេហទំព័ររបស់យើង www.ibac.vic.gov.au ព័ត៌មានលម្អិតអំពីរបៀបដែល IBAC ប្រមូល គ្រប់គ្រង ប្រើប្រាស់ និងបញ្ចេញព័ត៌មានផ្ទាល់ខ្លួន។ IBAC មានសិទ្ធិអនុញ្ញាតស្របច្បាប់ដើម្បីបញ្ចេញព័ត៌មានទៅមនុស្ស និងស្ថាប័ននានានៅខាងក្រៅនៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន។

វាជាបទល្មើសមួយក្នុងការប្តឹងតវ៉ាខុស ឬធ្វើឱ្យព័ត៌មានភាន់ច្រឡំដល់ IBAC។ ការផ្តល់ព័ត៌មានខុស ឬធ្វើឱ្យព័ត៌មានភាន់ច្រឡំដល់ IBAC ដោយមានឆន្ទៈ អាចនាំឱ្យមានការចោទប្រកាន់ជាបទឧក្រិដ្ឋ។

IBAC នឹងទាក់ទងអ្នកតែប្រសិនបើត្រូវការព័ត៌មានបន្ថែមទៀតប៉ុណ្ណោះ។ ប្រសិនបើអ្នកបានជ្រើសយកដើម្បីផ្តល់បណ្តឹងតវ៉ានេះជាអនាមិក នោះយើងមិនអាចទាក់ទងអ្នកបានទេ ហើយអ្នកនឹងមិនទទួលបានមតិត្រឡប់មកវិញស្តីពីលទ្ធផលនៃបណ្តឹងតវ៉ារបស់អ្នកទេ។

# សេចក្តីប្រកាស

☐ ចំពោះចំណេះដឹងដ៏ល្អបំផុតរបស់ខ្ញុំ ព័ត៌មានដែលបានផ្តល់នៅក្នុងបណ្តឹងតវ៉ានេះគឺត្រឹមត្រូវ។
☐ ខ្ញុំយល់ថាព័ត៌មាននៅក្នុងទម្រង់បែបបទនេះអាចត្រូវបានបញ្ចេញទៅឱ្យទីភ្នាក់ងារ ឬស្ថាប័នមួយផ្សេងទៀត។
☐ ខ្ញុំកំពុងធ្វើបណ្តឹងតវ៉ានេះជំនួសមុខឱ្យមនុស្សម្នាក់ផ្សេងទៀត ហើយបានបំពេញបញ្ចប់នៅឧបសម្ព័ន្ធ A។

| | |
|---|---|
| **ឈ្មោះ** | |
| **កាលបរិច្ឆេទ** | |

ជាន់ (Level) ទី 1,
North Tower
អាសយដ្ឋាន 459
Collins Street
Melbourne VIC 3000
GPO Box 24234
Melbourne VIC 3001

ទូរសព្ទ 1300 735 135
ទូរសារ (03) 8635 6444

IBAC គឺជាទីភ្នាក់ងារប្រឆាំងនឹងអំពើពុករលួយរបស់រដ្ឋវិចតូរៀ ទទួលខុសត្រូវក្នុងការទប់ស្កាត់ និងលាតត្រដាងឱ្យដឹងអំពីអំពើពុករលួយ ក្នុងផ្នែកសាធារណៈ និងការប្រព្រឹត្តិមិនត្រឹមត្រូវរបស់ប៉ូលីស។ យើងធ្វើកិច្ចការនេះដោយៈ

- ស៊ើបអង្កេតលើអំពើពុករលួយធ្ងន់ធ្ងរ និងការប្រព្រឹត្តិមិនត្រឹមត្រូវរបស់ប៉ូលីស
- ជូនដំណឹងដល់ផ្នែកសាធារណៈ ប៉ូលីស និងសហគមន៍អំពីហានិភ័យ និង
- ផលប៉ះពាល់នានានៃអំពើពុករលួយ និងការប្រព្រឹត្តិមិនត្រឹមត្រូវរបស់ប៉ូលីស ព្រមទាំងវិធីនានាដែលអាចទប់ស្កាត់រឿងនេះបាន។

ដើម្បីរាយការណ៍អំពីអំពើពុករលួយ និងការប្រព្រឹត្តិមិនត្រឹមត្រូវ សូមទូរសព្ទទៅលេខ **1300 735 135 ឬចូលមើល** www.ibac.vic.gov.au។

ទម្រង់បែបបទនេះមានច្រើនជាង 20 ភាសា នៅឯ www.ibac.vic.gov.au/mylanguage។ ប្រសិនបើអ្នកត្រូវការជំនួយដែលមានការបកប្រែសរសេរ ឬការទាក់ទងមកយើងជាភាសារបស់អ្នក សូមហៅទូរសព្ទទៅ សេវាបកប្រែផ្ទាល់មាត់ និងបកប្រែសរសេរ តាមលេខ 13 14 50។

# ឧបសម្ព័ន្ធ A – សិទ្ធិអនុញ្ញាតដើម្បីធ្វើសកម្មភាព

បំពេញផ្នែកនេះតែប្រសិនបើអ្នកយល់ព្រមចំពោះបណ្តឹងតវ៉ាដែលត្រូវបានធ្វើក្នុងនាមខ្លួនអ្នក ឬធ្វើសកម្មភាពសម្រាប់នរណាម្នាក់ប៉ុណ្ណោះ។

ខ្ញុំ

| (ឈ្មោះ) |
|---|

នៃ

| (អាសយដ្ឋាន) |
|---|

ពីពេលនេះទៅ អនុញ្ញាតិសិទ្ធិឱ្យ

| (ឈ្មោះ – បុគ្គល / អ្នកតំណាងស្របច្បាប់ / អង្គការ) |
|---|

នៃ

| (អាសយដ្ឋាន) |
|---|

ដើម្បីធ្វើសកម្មភាពក្នុងនាមខ្លួនខ្ញុំផ្ទាល់ ទាក់ទងនឹងបណ្តឹងតវ៉ារបស់ខ្ញុំទៅកាន់គណៈកម្មការប្រឆាំងអំពើពុករលួយដែលមានមូលដ្ឋានឯករាជ្យទូលំទូលាយ (**IBAC**)។

សិទ្ធិអនុញ្ញាតនេះរួមមាន៖

- ការទទួល និងការដាក់បញ្ជូនឯកសារក្នុងនាមខ្លួនខ្ញុំផ្ទាល់;
- ការទទួលបាន និងការផ្តល់ព័ត៌មានផ្ទាល់ខ្លួនដែលពាក់ព័ន្ធនឹងបណ្តឹងតវ៉ារបស់ខ្ញុំ និង
- ការធ្វើទំនាក់ទំនងជាមួយ IBAC ទាំងទំនាក់ទំនងផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ។

"សិទ្ធិអនុញ្ញាតដើម្បីធ្វើសកម្មភាព" ត្រូវបានកម្រិតកំណត់ចំពោះបណ្តឹងតវ៉ានេះ ហើយនៅតែមានសុពលភាពក្នុងពេលបណ្តឹងតវ៉ានេះកំពុងត្រូវបានពិចារណា ឬត្រូវបានស៊ើបអង្កេតដោយ IBAC, ប្រសិនបើខ្ញុំ មិនបានដកមុនទេ។ ខ្ញុំយល់ថា "សិទ្ធិអនុញ្ញាតដើម្បីធ្វើសកម្មភាព" អាចត្រូវបានដក ឬកែប្រែដោយខ្ញុំនៅពេលណាក៏បាន តាមរយៈការជូនដំណឹងទៅ IBAC ជាលាយលក្ខណ៍អក្សរ។

| | |
|---|---|
| **ឈ្មោះ** | |
| **កាលបរិច្ឆេទ** | |

**ហត្ថលេខា** ______________________________ (តម្រូវឱ្យមានហត្ថលេខា)

**សេចក្តីថ្លែងអំពីឯកជនភាព**
IBAC ប្តេជ្ញាចិត្តការពារប្រឆាំងនឹងការប្រើប្រាស់មិនត្រឹមត្រូវ ការបាត់បង់ ឬការបញ្ចេញព័ត៌មានផ្ទាល់ខ្លួនដែលមិនមានសិទ្ធិអនុញ្ញាតស្របតាម *ច្បាប់ឯកជនភាព និងការការពារទិន្នន័យឆ្នាំ 2014* និង *ច្បាប់កំណត់ត្រាសុខភាពឆ្នាំ 2001*, រួមទាំងគោលការណ៍ឯកជនភាពនៅក្នុងច្បាប់នីមួយៗផងដែរ។
សម្រាប់ព័ត៌មានបន្ថែមស្តីពីគោលការណ៍ឯកជនភាពរបស់ IBAC សូមមើល www.ibac.vic.gov.au.

---

**ការប្រើប្រាស់ផ្លូវការប៉ុណ្ណោះ**

| | |
|---|---|
| **លេខឯកសារ** | |
| **បានបញ្ចូលដោយ** | |